**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣ ❋ ៣

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
លេខ ០០៦ ស.អ.យ.

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៤*

# សារាចរណែនាំ
## ស្តីពី
## ការបន្ថែមប្រាក់សោធនប្រចាំខែជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តស្របតាមស្មារតីអនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបន្ថែមប្រាក់សោធនប្រចាំខែជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដូចតទៅ ៖

**១** . គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត ត្រូវអនុវត្តលើកគម្រោងបន្ថែមប្រាក់សោធនប្រចាំខែ ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល ស្របតាមនីតិវិធីជាធរមាន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ តទៅ តាមប្រភេទក្របខ័ណ្ឌ ដូចខាងក្រោម ៖

- ក្របខ័ណ្ឌប្រភេទ **ក** ចំនួន ២០.០០០ រៀល ( ម្ភៃពាន់រៀល )
- ក្របខ័ណ្ឌប្រភេទ **ខ** ចំនួន ២០.០០០ រៀល ( ម្ភៃពាន់រៀល )
- ក្របខ័ណ្ឌប្រភេទ **គ** ចំនួន ៤០.០០០ រៀល ( សែសិបពាន់រៀល )
- ក្របខ័ណ្ឌប្រភេទ **ឃ** ចំនួន ៦០.០០០ រៀល ( ហុកសិបពាន់រៀល )

**២** . គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត ត្រូវអនុវត្តនីតិវិធី នៃការផ្ទេរឥណទានរបបសន្តិសុខសង្គមជូនសិទ្ធិវន្ត នៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ឱ្យបានទាន់ពេលវេលា ស្របតាមស្មារតីសារាចរលេខ ០៤ .សរ. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល។

**៣** . គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត ត្រូវអនុវត្តលើកគម្រោងរបបសន្តិសុខសង្គមប្រចាំខែ ប្រចាំឆ្នាំ ជូនសិទ្ធិវន្ត នៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រហូតដល់មូលនិធិសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានដំណើរការ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត ត្រូវអនុវត្តជាកិច្ចការប្រញាប់ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ឱ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព ។

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន✓
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស.
- សាលារាជធានី-ខេត្ត
  " ដើម្បីជូនជ្រាប "
- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ស.អ.យ.
  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation. #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086